សំណើ
# 2 ផ្តល់សិទ្ធិមូលបត្រសម្រាប់សាលាសាធារណៈ និងបរិក្ខាមហាវិទ្យាល័យសហគមន៍។ លក្ខន្តិកៈច្បាប់។

**ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប** រៀបចំដោយអគ្គព្រះរាជអាជ្ញា

**អត្ថបទស្តីពីវិធានការនេះអាចរកបាននៅទំព័រទី 70 និងនៅវ៉ិបសាយថ៍រដ្ឋលេខាធិការតាមរយ *voterguide.sos.ca.gov*។**

- ផ្តល់សិទ្ធិ $10 ពាន់លានដុល្លារនៅក្នុងមូលបត្រកាតព្វកិច្ចទូទៅរបស់រដ្ឋសម្រាប់ការជួសជុល ធ្វើឱ្យប្រសើរឡើង និងការសាងសង់កន្លែងនៅសាលារដ្ឋ K–12 (រួមទាំងសាលាធម្មនុញ្ញ) និងមហាវិទ្យាល័យសហគមន៍។
- ផ្តល់មូលនិធិសម្រាប់សម្ភារៈបរិក្ខារថ្មី កែលម្អសុខភាពសាលារៀន និងលក្ខខណ្ឌសុវត្ថិភាពនៅបរិក្ខារដែលមានស្រាប់ និងសម្រាប់ថ្នាក់រៀន ការធ្វើឱ្យប្រសើរឡើង (ឧ. វិទ្យាសាស្ត្រ វិស្វកម្ម សាលាមត្តេយ្យអន្តរកាល និងថ្នាក់រៀនវិជ្ជាជីវៈ)។
- ពង្រីកសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់មណ្ឌលសិក្សាតូចៗ និងជួបការលំបាក។
- ផ្តល់ភាគរយខ្ពស់នៃមូលនិធិផ្គូផ្គងរដ្ឋដល់សាលារៀនដែលបង្ហាញពីតម្រូវការខ្ពស់បំផុត។
- តម្រូវឱ្យមានសវនាការសាធារណៈ និងសវនកម្មលើការអនុវត្ត។
- ប្រាក់សមរម្យពីមូលនិធិទូទៅដើម្បីសងមូលបត្របំណុល។

### សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិ អំពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ការចំណាយរបស់រដ្ឋបានកើនឡើងប្រហែល $500 លានដុល្លារជារៀងរាល់ឆ្នាំសម្រាប់រយៈពេល 35 ឆ្នាំដើម្បីសងបំណុលវិញ។

| ការប៉ាន់ស្មានតម្លៃមូលបត្របំណុលរដ្ឋ | |
|---|---|
| ចំនួនដែលបានខ្ចី | $10 ពាន់លានដុល្លារ |
| ការចំណាយលើការទូទាត់ជាមធ្យម | $500 លានដុល្លារក្នុងមួយឆ្នាំក្នុងរយៈពេល 35 ឆ្នាំ |
| ប្រភពនៃការទូទាត់សង | ប្រាក់ចំណូលពន្ធទូទៅ |

ការបោះឆ្នោតជ្រើសរើសចុងក្រោយដោយអង្គនីតិបញ្ញត្តិនៅលើ AB 247 (សំណើ 2)
(ជំពូកទី 81 លក្ខន្តិកៈឆ្នាំ 2024)

| | | |
|---|---|---|
| ព្រឹទ្ធសភា៖ | បោះឆ្នោតគាំទ្រ 34 | បដិសេធ 3 |
| សភា៖ | បោះឆ្នោតគាំទ្រ 72 | បដិសេធ 1 |

**ការវិភាគដោយអ្នកវិភាគច្បាប់**

## ផ្ទៃខាងក្រោយ

***រដ្ឋ California មានសាលារដ្ឋ និងមហាវិទ្យាល័យសហគមន៍ជាច្រើន។*** បច្ចុប្បន្ននេះ មានសាលារដ្ឋប្រហែល 10,000 នៅទូទាំងរដ្ឋ (រួមមានប្រហែល 1,300 សាលារៀនឯករាជ្យ)។ សាលារៀនទាំងនេះមានសិស្សចាប់ពីថ្នាក់បឋមសិក្សា រហូតដល់វិទ្យាល័យ។ អាជ្ញាធរសាលាក្នុងតំបន់គ្រប់គ្រងសាលារៀនរដ្ឋទាំងនេះភាគច្រើន។ រដ្ឋ California ក៏មានមហាវិទ្យាល័យសហគមន៍ក្នុងតំបន់ចំនួន 115 ដែលផ្តល់ការអប់រំកម្រិតសញ្ញាបត្ររង និងកម្មវិធីផ្សេងទៀតសម្រាប់មនុស្សពេញវ័យ។ អាជ្ញាធរមហាវិទ្យាល័យសហគមន៍ក្នុងតំបន់គ្រប់គ្រងមហាវិទ្យាល័យទាំងនេះ។ អាជ្ញាធរសាលារៀន និងមហាវិទ្យាល័យសហគមន៍ ជាធម្មតាសាងសង់អគារថ្មីនៅពេលដែលសាលារៀនទាំងនោះ កំពុងមានកំណើនសិស្សចុះឈ្មោះ ហើយត្រូវការកន្លែងបន្ថែម។ ពួកគេជួសជុលកែលម្អអគារដែលមានស្រាប់ នៅពេលដែលអគារទាំងនោះចាស់ ឬមិនមានសុវត្ថិភាព។

## ការវិភាគដោយ អ្នកវិភាគច្បាប់

បន្ត

***រដ្ឋ និងអាជ្ញាធរសាលាជាធម្មតាបែងចែកខ្ទង់ចំណាយលើសម្ភារៈបរិក្ខារអប់រំ។*** សម្រាប់អាជ្ញាធរសាលារៀនរដ្ឋ រដ្ឋជាធម្មតាបង់ 50 ភាគរយ សម្រាប់ថ្លៃចំណាយលើគម្រោងសាងសង់ថ្មីៗ និង 60 ភាគរយ សម្រាប់ថ្លៃចំណាយលើគម្រោងជួសជុលកែលម្អ។ អាជ្ញាធរសាលារៀនរំពឹងថា ត្រូវបង់ថ្លៃចំណាយគម្រោងសេសសល់តាមរយៈការប្រើប្រាស់មូនិធិក្នុងតំបន់។ រដ្ឋក៏ជារឿយៗបែងចែកថ្លៃចំណាយលើគម្រោងសាងសង់ថ្មីៗ និងជួសជុលកែលម្អជាមួយអាជ្ញាធរមហាវិទ្យាល័យសហគមន៍ផងដែរ។ ទោះបីជាការបែងចែកខ្ទង់ចំណាយខុសគ្នាក្នុងចំណោមគម្រោងទាំងឡាយក៏ដោយ រដ្ឋជាទូទៅចំណាយប្រហែលពាក់កណ្តាលនៃថ្លៃចំណាយ ចំណែកឯអាជ្ញាធរមហាវិទ្យាល័យសហគមន៍ ត្រូវបង់ថ្លៃចំណាយដែលនៅសេសសល់តាមរយៈប្រើមូលនិធិក្នុងតំបន់។

***រដ្ឋប្រើប្រាស់ប័ណ្ណបំណុលជាចម្បងដើម្បីទូទាត់ខ្ទង់ចំណាយរបស់ខ្លួន។*** ប័ណ្ណបំណុល គឺជាមធ្យោបាយដែលរដ្ឋខ្ចីប្រាក់ រួចបង់សងវិញ បូកនឹងការប្រាក់តាមពេលវេលា។ សម្រាប់ព័ត៌មានបន្ថែមអំពីប័ណ្ណបំណុល សូមមើល “ទិដ្ឋភាពទូទៅស្តីពីបំណុលលើប័ណ្ណបំណុលរដ្ឋ” នៅពេលក្រោយនៅក្នុងសេចក្តីណែនាំនេះ។) ក្នុងរយៈពេល 20 ឆ្នាំកន្លងមកនេះ ការផ្តល់មូលនិធិសម្ភារៈបរិក្ខាររបស់រដ្ឋសម្រាប់សាលារៀន និងមហាវិទ្យាល័យសហគមន៍ភាគច្រើនបានមកពីប័ណ្ណបំណុលដែលអនុម័តដោយអ្នកបោះឆ្នោត (សរុបជាទឹកប្រាក់ $31.8 ពាន់លានដុល្លារ)។ ថ្មីៗនេះ រដ្ឋបានផ្តល់ថវិកាបន្ថែមចំនួន $4.6 ពាន់លានដុល្លារបន្ថែមទៀត សម្រាប់អគារសិក្សារបស់សាលារៀន និងមហាវិទ្យាល័យសហគមន៍។ មូលនិធិស្ទើរតែទាំងអស់ ត្រូវបានផ្តល់សម្រាប់គម្រោងជាក់លាក់រួចហើយ។

***ជាធម្មតា អាជ្ញាធរសាលាត្រូវបង់ខ្ទង់ចំណាយរបស់ខ្លួនដោយប្រើប័ណ្ណបំណុលក្នុងតំបន់។*** អាជ្ញាធរសាលារៀន និងមហាវិទ្យាល័យសហគមន៍ មានទំនោរបង់ខ្ទង់ចំណាយលើគម្រោងរបស់ខ្លួនដោយប្រើប័ណ្ណបំណុលក្នុងតំបន់។ អាជ្ញាធរសាលា ត្រូវតែរកឱ្យបានបានយ៉ាងហោចណាស់ 55 ភាគរយ នៃសំឡេងគាំទ្ររបស់អ្នកបោះឆ្នោតរបស់ខ្លួន ដើម្បីអនុម័តការលក់ប័ណ្ណបំណុលក្នុងតំបន់។ ច្បាប់រដ្ឋកំណត់ចំនួនប័ណ្ណបំណុលក្នុងតំបន់សរុប ដែលអាជ្ញាធរមានសាលារៀន និងមហាវិទ្យាល័យសហគមន៍ អាចចេញ។ ការកំណត់ទាំងនេះគឺផ្អែកលើតម្លៃអចលនទ្រព្យដែលបានវាយតម្លៃសរុបនៅក្នុងស្រុក។ អាជ្ញាធរសាលារៀនដែលមិនអាចរៃអង្គាសប្រាក់បានយ៉ាងហោចណាស់ $5 លានដុល្លារក្រោមដែនកំណត់ទាំងនេះ អាចស្នើសុំមូលនិធិរដ្ឋបន្ថែមបាន។ ក្នុងរយៈពេល 20 ឆ្នាំកន្លងមកនេះ អ្នកបោះឆ្នោតបានអនុម័តលើទឹកប្រាក់ចំនួន $181 ពាន់លានដុល្លារ នៅក្នុងប័ណ្ណបំណុលក្នុងតំបន់ សម្រាប់គម្រោងសម្ភារៈបរិក្ខារសាលារៀនរដ្ឋ និងមហាវិទ្យាល័យសហគមន៍។

## សំណើ

***ប័ណ្ណបំណុលថ្មីសម្រាប់សម្ភារៈបរិក្ខាសាលាសារៀនរដ្ឋ និងមហាវិទ្យាល័យសហគមន៍។*** សំណើ 2 អនុញ្ញាតឱ្យរដ្ឋលក់ប័ណ្ណបំណុលចំនួន $10 ពាន់លានដុល្លារ សម្រាប់សម្ភារៈបរិក្ខាសាលាសារៀនរដ្ឋ និងមហាវិទ្យាល័យសហគមន៍។ ដូចរូបភាព 1 បានបង្ហាញ ទឹកប្រាក់ចំនួន $8.5 ពាន់លានដុល្លារ សម្រាប់សាលារៀនរដ្ឋ (ឬ 85 ភាគរយនៃចំនួនប័ណ្ណបំណុលសរុប) ត្រូវបានបែងចែក

រូបភាព 1

**ការប្រើប្រាស់មូលនិធិប័ណ្ណបំណុលដែលបានស្នើឡើង**
(ជាពាន់លាន)

| | |
|---|---|
| **គ្រឿងបរិក្ខារសាលាសាធារណៈ** | **$8.5** |
| ការជួសជុលកែលម្អអគារដែលមានស្រាប់ | $4.0 |
| សំណង់ថ្មី (រួមទាំងការទិញដី) | 3.3 |
| ឧបករណ៍សម្រាប់កម្មវិធីអប់រំបច្ចេកទេសអាជីព | 0.6 |
| សាលាសាធារណៈឯកជន | 0.6 |
| **គ្រឿងបរិក្ខារមហាវិទ្យាល័យសហគមន៍** | **$1.5** |
| **សរុប** | **$10.0** |

សម្រាប់អត្ថបទពេញលេញស្តីពីសំណើ 2 សូមមើលទំព័រទី 70 ។

**ការវិភាគដោយ អ្នកវិភាគច្បាប់** បន្ត

ក្នុងចំណោមគម្រោងសម្ភារៈបរិក្ខារចំនួនបួនប្រភេទ។ សម្រាប់គម្រោងសាងសង់ និងជួសជុលកែលម្អថ្មីៗ អាជ្ញាធរសាលារៀន នឹងដាក់ពាក្យស្នើសុំ និងទទួលបាន មូលនិធិជាចម្បងលើមូលដ្ឋានកំណត់មកមុនបានមុន។ រដ្ឋនឹងផ្តល់មូលនិធិលើការអប់រំបច្ចេកទេសអាជីព និង មូលនិធិសម្រាប់សាលារៀនឯករាជ្យ តាមរយៈដំណើរការ ដាក់ពាក្យដែលមានការប្រកួតប្រជែង។ មូលនិធិសាងសង់ និងជួសជុលកែលម្អថ្មីៗ ក្នុងចំណែកតូចមួយ ត្រូវទុកមួយ ឡែកសម្រាប់អាជ្ញាធរសាលារៀនតូច។ មិនដូចមូលនិធិ សម្រាប់សាលារដ្ឋទេ ទឹកប្រាក់ចំនួន $1.5 ពាន់លានដុល្លារសម្រាប់មហាវិទ្យាល័យសហគមន៍ (ឬ 15 ភាគរយនៃចំនួនទឹកប្រាក់ប័ណ្ណបំណុលសរុប) មិនត្រូវបានបែងចែកតាមវិធីកំណត់ក្នុងចំណោមប្រភេទ គម្រោងជាក់លាក់នោះទេ។ មូលនិធិប័ណ្ណបំណុល មហាវិទ្យាល័យសហគមន៍ អាចត្រូវបានប្រើប្រាស់សម្រាប់ ការដាក់បញ្ចូលគ្នាទៅលើអគារថ្មីៗ ការជួសជុលកែលម្អ ការទិញដី និងសម្ភារៈបរិក្ខារ។ មហាវិទ្យាល័យសហគមន៍ នឹងរៀបចំផែនការដោយមានរាយបញ្ជីអាទិភាពគម្រោង ទូទាំងរដ្ឋរបស់ខ្លួន។ អភិបាល និងអង្គនីតិប្បញ្ញត្តិនឹង ជ្រើសរើសគម្រោងជាក់លាក់ដើម្បីផ្តល់មូលនិធិ។ សំណើ 2 តម្រូវឱ្យអាជ្ញាធរសាលាបញ្ចប់កិច្ចការជាក់លាក់ដើម្បី ជួយធានាថា ប័ណ្ណបំណុលត្រូវបានចំណាយតាមការ គ្រោងទុក។

***មូលនិធិជួសជុលកែលម្អមួយចំនួនមានសម្រាប់ប្រភេទ គម្រោងសាលារៀនជាក់លាក់។*** សំណើ 2 អនុញ្ញាត ឱ្យប្រើប្រាស់មូលនិធិរហូតដល់ទឹកប្រាក់ $115 លាន ដុល្លារសម្រាប់កាត់បន្ថយកម្រិតសំណនៅក្នុងទឹកតាម ទីតាំងសាលារៀនរដ្ឋ។ សំណើ 2 ក៏អនុញ្ញាតឱ្យអាជ្ញាធរ សាលារៀន ទទួលបានមូលនិធិជួសជុលកែលម្អបន្ថែម សម្រាប់បង្កើតថ្នាក់រៀនថ្មី ឬជួសជុលកែលម្អថ្នាក់រៀន ដែលមានស្រាប់ ដែលនឹងត្រូវបានប្រើសម្រាប់សាលា មត្តេយ្យអន្តរកាល។ (ចាប់ផ្តើមពីឆ្នាំសិក្សា 2025–26 កុមារអាយុ បួន ឆ្នាំទាំងអស់ នឹងមានសិទ្ធិចូលរៀននៅ សាលាមត្តេយ្យអន្តរកាលមួយឆ្នាំ មុនពេលចូលរៀន មត្តេយ្យ។) ក្នុងករណីខ្លះ អាជ្ញាធរសាលារៀន ក៏អាច ទទួលបានមូលនិធិជួសជុលកែលម្អបន្ថែម ដើម្បីពង្រីក ឬ សាងសង់កន្លែងហ្វឹកហាត់ បន្ទប់ពហុមុខងារ បណ្ណាល័យ ឬផ្ទះបាយក្នុងសាលារៀនផងដែរ។

***បង្កើនខ្ទង់ចំណាយរបស់រដ្ឋសម្រាប់អាជ្ញាធរសាលារៀន មួយចំនួន។*** សម្រាប់អាជ្ញាធរសាលារៀនមួយចំនួន សំណើទី 2 បង្កើនខ្ទង់ចំណាយរបស់រដ្ឋទៅលើគម្រោង សាងសង់ថ្មីពី 50 ភាគរយ ទៅ 55 ភាគរយ។ សំណើ 2 ក៏បង្កើនខ្ទង់ចំណាយរបស់រដ្ឋសម្រាប់គម្រោងជួសជុល កែលម្អពី 60 ភាគរយ ទៅ 65 ភាគរយសម្រាប់អាជ្ញាធរ សាលារៀនទាំងនេះ។ ជាទូទៅ រដ្ឋនឹងបង់ខ្ទង់ចំណាយ លើគម្រោងកាន់តែខ្ពស់សម្រាប់អាជ្ញាធរសាលារៀន ដែល មានតម្លៃអចលនទ្រព្យដែលបានវាយតម្លៃទាប ព្រមទាំង មានខ្ទង់ចំណាយកាន់តែខ្ពស់សម្រាប់សិស្សរបស់ពួកគេ ដែលមានប្រាក់ចំណូលទាប អ្នកសិក្សាភាសាអង់គ្លេស ឬ យុវជនក្នុងគម្រោងចិញ្ចឹមបីបាច់។

***អនុញ្ញាតឱ្យអាជ្ញាធរសាលារៀនដាក់ពាក្យស្នើសុំមូលនិធិ រដ្ឋបន្ថែមឱ្យបានច្រើន*** សំណើ 2 អនុញ្ញាតឱ្យអាជ្ញាធរ សាលារៀន ដែលមិនមានលទ្ធភាពរៃអង្គាសប្រាក់ យ៉ាងហោចណាស់ ទឹកប្រាក់ចំនួន $15 លានដុល្លារ ពីប័ណ្ណបំណុលក្នុងតំបន់ (ចាប់ពី $5 លានដុល្លារ) ដើម្បីស្នើសុំមូលនិធិរដ្ឋបន្ថែម។ ចំនួនទឹកប្រាក់នេះនឹង កើនឡើងដោយសារកត្តាអតិផរណានៅឆ្នាំខាងមុខ។

## ផលប៉ះពាល់សារពើពន្ធ

***ការចំណាយរបស់រដ្ឋកើនឡើងប្រហែល $500 លានដុល្លាររៀងរាល់ឆ្នាំសម្រាប់រយៈពេល 35 ឆ្នាំដើម្បី សងប័ណ្ណបំណុល។*** ការចំណាយប៉ាន់ស្មានដើម្បីសង ប័ណ្ណបំណុលនឹងមាន **ប្រហែល $500 លានដុល្លារ ជា រៀងរាល់ឆ្នាំ (ប្រចាំឆ្នាំ) ក្នុងរយៈពេល 35 ឆ្នាំ**។ ការទូទាត់ នឹងត្រូវធ្វើឡើងពីមូលនិធិទូទៅរបស់រដ្ឋ។ (មូលនិធិទូទៅ គឺជាគណនីដែលរដ្ឋប្រើដើម្បីបង់ថ្លៃសេវាសាធារណៈ ភាគច្រើន រួមទាំងការអប់រំ ការថែទាំសុខភាព និង ពន្ធនាគារ។) មូលនិធិនេះនឹងមានតិចជាងពាក់កណ្តាល 1 ភាគរយនៃកញ្ចប់ថវិកានៃមូលនិធិទូទៅសរុបរបស់

រដ្ឋ។ ដោយសាររដ្ឋត្រូវបង់ការប្រាក់លើថវិកាដែលខ្លួនខ្ចីនោះ ការចំណាយសរុបលើប័ណ្ណបំណុលនឹងមានប្រហែល 10 ភាគរយ (បន្ទាប់ពីកែតម្រូវអតិផរណា) ច្រើនជាង ប្រសិនបើរដ្ឋបង់មុនដោយប្រើប្រាក់ដែលខ្លួនមានរួចហើយ។

***ឥទ្ធិពលមិនច្បាស់លាស់លើការចំណាយក្នុងតំបន់ទូទាំងរដ្ឋ។*** លទ្ធភាពទទួលបានមូលនិធិប័ណ្ណបំណុលរដ្ឋ អាចប៉ះពាល់ដល់ការចំណាយក្នុងតំបន់របស់អាជ្ញាធរសាលាមួយចំនួន។ ឧទាហរណ៍ ស្រុកមួយចំនួនអាចឆ្លើយតបដោយការស្វែងរកប័ណ្ណបំណុលក្នុងតំបន់ថ្មី ដើម្បីជួយពួកគេបំពេញតម្រូវការស្របទៅនឹងគម្រោង។ ស្រុកទាំងនេះនឹងឃើញការចំណាយក្នុងតំបន់របស់ខ្លួនកើនឡើង។ ផ្ទុយទៅវិញ ស្រុកផ្សេងទៀតអាចឆ្លើយតបតាមរយៈការខ្ចីប្រាក់តិច ព្រោះមូលនិធិរដ្ឋអាចបង់ការចំណាយដែលស្រុករ៉ាប់រងដោយខ្លួនឯងនេះ។ ស្រុកទាំងនេះនឹងឃើញការចំណាយក្នុងតំបន់របស់ខ្លួនថយចុះ។ សរុបមក ឥទ្ធិពលលើការចំណាយក្នុងតំបន់ទូទាំងរដ្ឋគឺមិនច្បាស់លាស់ទេ។

**សូមចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2024-ballot-measure-contribution-totals* សម្រាប់បញ្ជី គណៈកម្មាធិការ បង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងវិធានការនេះ។**

**សូមចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលអ្នកជួយវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**